ក្រសួងសុខាភិបាល រដ្ឋញូវសៅវែល (NSW Health)

វ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B

សន្លឹកព័ត៌មានសម្រាប់ឪពុកម្តាយ

រដ្ឋាភិបាលអូស្ត្រាលីផលិតវ៉ាក់សាំងមួយចំនួនដោយឥតគិតថ្លៃនៅក្រោមកម្មវិធីចាក់ថ្នាំបង្ការថ្នាក់ជាតិ (NIP)។

សំណួរ៖ តើជំងឺរលាកថ្លើមប្រភេទ B ជាអ្វី?

ជំងឺរលាកថ្លើមប្រភេទ B គឺជាវីរុសមួយដែលអាចបណ្តាលឱ្យក្តៅខ្លួន កើតជំងឺខាន់លឿង និងមានអារម្មណ៍មិនស្រួលខ្លួន។ វាអាចបណ្តាលឱ្យខូចថ្លើម (ក្រិនថ្លើម) ឬមហារីកថ្លើម។ មនុស្សមួយចំនួនប្រហែលជាមិនដឹងថាខ្លួនមានជំងឺរលាកថ្លើមប្រភេទ B ទេ ហើយអាចចម្លងទៅអ្នកដទៃ។

សំណួរ៖ តើជំងឺរលាកថ្លើមប្រភេទ B ឆ្លងរាលដាលយ៉ាងដូចម្តេចដែរ?

ជំងឺរលាកថ្លើមប្រភេទ B ឆ្លងរាលដាលតាមរយៈ៖

- **កំណើត (ពីម្តាយដែលបានឆ្លងរោគ ទៅកូនរបស់នាង)**
- **ប៉ះពាល់ជាមួយដំបៅ ឬរបួសបើកចំហ**
- **ការរួមភេទដែលមិនមានសុវត្ថិភាព**
- **របួសពីការមុតម្ជុល**
- **ការសាក់ ឬចោះដោយឧបករណ៍មិនស្អាត**
- **ការប្រើប្រាស់ម្ជុលរួមគ្នា។**

សំណួរ៖ តើវ៉ាក់សាំងដំណើរការយ៉ាងដូចម្តេច?

វ៉ាក់សាំងជួយប្រព័ន្ធភាពស៊ាំរបស់អ្នកប្រឆាំងនឹងការឆ្លងមេរោគ។ ប្រសិនបើមនុស្សដែលបានចាក់វ៉ាក់សាំងប៉ះពាល់នឹងការឆ្លងមេរោគទាំងនេះ ប្រព័ន្ធភាពស៊ាំរបស់ពួកគេអាចទប់ទល់នឹងជំងឺនេះបានប្រសើរជាងមុន ទាំងការទប់ស្កាត់ការវិវត្តនៃជំងឺ ឬធ្វើឱ្យវាមិនសូវធ្ងន់ធ្ងរ។

សំណួរ៖ តើវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B មានប្រសិទ្ធភាពយ៉ាងណាដែរ?

វ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B ផ្តល់ការការពារយ៉ាងរឹងមាំប្រឆាំងនឹងវីរុស។

សំណួរ៖ តើត្រូវការវ៉ាប៉ុន្មានដូស?

- **កុមារ និងមនុស្សវ័យជំទង់ដែលមានអាយុពី 10-19 ឆ្នាំ ត្រូវការ 3 ដូសសម្រាប់កុមារ ឬ**
- **កុមារ និងមនុស្សវ័យជំទង់ដែលមានអាយុពី 11 ទៅ 15 ឆ្នាំអាចចាក់ 2 ដូសសម្រាប់មនុស្សពេញវ័យ លុះត្រាតែពួកគេធ្លាប់បានចាក់វ៉ាក់សាំងកាលពីនៅទារក ឬកូនក្មេង។**

សំណួរ៖ តើអ្នកណាគួរចាក់វ៉ាក់សាំង?

កុមារ និងមនុស្សវ័យជំទង់ទាំងអស់ដែលមិនបានចាក់វគ្គពេញលេញនៃវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B គួរតែត្រូវបានចាក់វ៉ាក់សាំងនេះ។

សំណួរ៖ តើអ្នកណាមិនគួរចាក់វ៉ាក់សាំង?

កុំចាក់វ៉ាក់សាំងដល់មនុស្សដែល៖

- **មានប្រតិកម្មអាលែហ្សីធ្ងន់ធ្ងរ (ប្រតិកម្មអាណាហ្វីឡាក់ទិច) ទៅនឹងដូសពីមុន ឬសារធាតុផ្សំនៅក្នុងវ៉ាក់សាំង**
- **មានផ្ទៃពោះ។**

សំណួរ៖ តើវ៉ាក់សាំងមានសុវត្ថិភាពប៉ុណ្ណាដែរ?

វ៉ាក់សាំងនៅប្រទេសអូស្ត្រាលីមានសុវត្ថិភាពណាស់។ វ៉ាក់សាំងត្រូវតែឆ្លងកាត់ការត្រួតពិនិត្យសុវត្ថិភាពយ៉ាងតឹងរឹង មុនពេលមានការអនុម័តដោយរដ្ឋបាលគ្រប់គ្រងលើទំនិញទាក់ទងនឹងការព្យាបាល (TGA)។ TGA ក៏តាមដានលើសុវត្ថិភាពវ៉ាក់សាំងផងដែរបន្ទាប់ពីការប្រើប្រាស់រួច។

សំណួរ៖ តើវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B មានផ្ទុកសារធាតុអ្វីខ្លះ?

វ៉ាក់សាំងនេះមានផ្ទុក៖

- **អាលុយមីញ៉ូអ៊ីដ្រូស៊ីតដើម្បីជួយឱ្យវាដំណើរការ**
- **ប្លូតេអ៊ីនដំបែរ (អាចមានវត្តមាន)**
- **សារធាតុពីសន្លានគោ (អាចមានវត្តមាន)។**

សំណួរ៖ តើវ៉ាក់សាំងមានផលប៉ះពាល់បន្ទាប់បន្សំអ្វីខ្លះ?

ផលប៉ះពាល់បន្ទាប់បន្សំជាធម្មតាស្រាល ហើយអាចរួមមាន៖

- **ការឈឺចាប់ ក្រហម ឬការហើមនៅកន្លែងចាក់វ៉ាក់សាំង។**

ផលប៉ះពាល់បន្ទាប់បន្សំធ្ងន់ធ្ងរគឺកម្រមានណាស់។

សម្រាប់ព័ត៌មានបន្ថែម សូមពិនិត្យមើលព័ត៌មានឱសថសម្រាប់អ្នកប្រើប្រាស់ (CMI) នៅតាមគេហទំព័រ health.nsw.gov.au/schoolvaccination។ ប្រសិនបើអ្នកព្រួយបារម្ភអំពីផលប៉ះពាល់បន្ទាប់បន្សំ សូមទាក់ទង GP (វេជ្ជបណ្ឌិតព្យាបាលជំងឺទូទៅ) របស់អ្នក។

សំណួរ៖ តើអ្វីទៅប្រតិកម្មអាណាហ្វីឡាក់ទិច (anaphylaxis)?

ប្រតិកម្មអាណាហ្វីឡាក់ទិចគឺជាប្រតិកម្មអាឡែហ្ស៊ីដ៏កម្រ ប៉ុន្តែធ្ងន់ធ្ងរ។ វាអាចបណ្តាលឱ្យសន្លប់ ឬស្លាប់ ប្រសិនបើមិនបានព្យាបាលឱ្យបានឆាប់រហ័ស។ អ្នកផ្តល់សេវាចាក់ថ្នាំបង្ការត្រូវបានបណ្តុះបណ្តាលដើម្បីគ្រប់គ្រងប្រតិកម្មអាណាហ្វីឡាក់ទិចនេះ។

សំណួរ៖ ចុះបើខ្ញុំមិនមានកំណត់ត្រា ឬមិនអាចចាំបានថាកូនរបស់ខ្ញុំបានចាក់វ៉ាក់សាំងរួចហើយ?

វាមានសុវត្ថិភាពសម្រាប់កូនរបស់អ្នកក្នុងការចាក់វគ្គវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B មួយទៀត។